# ឯកសារឧស្សនដាន សម្រាប់សិក្ខាសាលាថ្នាក់តំបន់ស្តីពី

## និន្នាការអភិវឌ្ឍន៍សម្រាប់អង្គការសង្គមស៊ីវិល

ថ្ងៃទី៣១ ខែតុលា និងព្រឹកថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅសណ្ឋាគារ ហ៊រ ប៊ុន្នី ទីរួមខេត្តក្រចេះ

## បុព្វកថា

ស្របពេលមានការរីកចម្រើនយ៉ាងឆាប់រហ័សទាំងបរិបទសាកលលោក ក៏ដូចជានៅកម្ពុជា ទាំងផ្នែកបច្ចេកវិទ្យាព័ត៌មាន សេដ្ឋកិច្ចនយោបាយ សេដ្ឋកិច្ចសង្គម ផែនការអភិវឌ្ឍសាកល ក៏ដូចជាបទដ្ឋាន និងគោលនយោបាយជាច្រើន ដែលត្រូវបានរៀបចំឡើង ដើម្បីស្របតាមដំណើរការអភិវឌ្ឍទាំងនេះនៅកម្ពុជា។ ជាក់ស្តែងថ្មីៗនេះ យើងសង្កេតឃើញកំណើនសេដ្ឋកិច្ចកម្ពុជា នៅតែបន្តលូតលាស់ ស្របជាមួយការធ្លាក់ចុះនូវហិរញ្ញប្បទានសម្រាប់សង្គមស៊ីវិល ព្រមទាំងមានការណែនាំ និងគោលនយោបាយថ្មីជាច្រើន ត្រូវបានយកមកអនុវត្តសម្រាប់អង្គការសង្គមស៊ីវិល រួមមាន៖ ច្បាប់ស្តីពីពន្ធដារ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងគោលនយោបាយផ្សេងៗទៀតជាច្រើន សម្រាប់ដំណើរដល់ការងារអភិវឌ្ឍន៍ ក៏ដូចជាប្រតិបត្តិការសម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា។ ជាងនេះទៅទៀត ផែនការអភិវឌ្ឍថ្មីសម្រាប់សាកលលោក ដែលជារបៀបវារៈសម្រាប់ការអភិវឌ្ឍក្រោយឆ្នាំ២០១៥ ក៏ដូចជាផែនការអភិវឌ្ឍថ្នាក់ក្រោមជាតិដំណាក់កាលទីបី និងការអនុវត្តផែនការគណនេយ្យភាពសង្គម កំពុងត្រូវបានរៀបចំធ្វើមូលដ្ឋាននីយកម្មសម្រាប់កម្ពុជា និងពិភាក្សាក្នុងការរៀបចំ និងអនុវត្ត។

ដូច្នេះហើយ ដើម្បីអោយដំណើរការ និងនិន្នាការនៃការផ្លាស់ប្តូរនេះ ប៉ះពាល់ជាវិជ្ជមាន និងអាចអនុវត្តដំណើរការដោយរលូនស្របតាមបរិបទទាំងនេះ អង្គការសង្គមស៊ីវិល ក៏ដូចជាសម្រាប់ការអនុវត្តការងាររួមគ្នាក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាល គួររៀបចំយន្តការ និងគំនិតផ្តួចផ្តើមថ្មីៗ ដើម្បីផ្សារភ្ជាប់សកម្មភាពការងារ និងការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក ព្រមទាំងមានការប្រាស្រ័យទាក់ទងគ្នា ដែលមានប្រសិទ្ធភាពសម្រាប់ស្ថាប័ន ក៏ដូចជារវាង បណ្តាញអង្គការនៅតាមបណ្តាខេត្ត និងបណ្តាញអង្គការថ្នាក់ជាតិ ក្នុងការឆ្លើយតបអោយកាន់តែមានភាពប្រសើរឡើង និងដោយរលូន។

អាស្រ័យហេតុនេះ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ជាអង្គការសមាជិកភាព ដែលត្រូវបានបង្កើតឡើងតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ និងមានតួនាទីក្នុងការជួយសម្របសម្រួល និងកសាងសមត្ថភាពសម្រាប់អង្គការសមាជិក និងដៃគូអភិវឌ្ឍផ្សេងទៀត ព្រមទាំងជាដៃគូអភិវឌ្ឍន៍ជាមួយរាជរដ្ឋាភិបាល។ ជាងនេះទៀត អង្គការ CCC មានបទពិសោធន៍ក្នុងការរៀបចំសិក្ខាសាលាថ្នាក់តំបន់ជារៀងរាល់ឆ្នាំ ដែលមានការចូលរួមសហការជាមួយអង្គការសមាជិក និងបណ្តាញ

អង្គការថ្នាក់ខេត្ត ជាអាទិ៍ធ្លាប់មានកិច្ចសហការជាមួយអង្គការមនុស្សចាស់កម្ពុជា ខេត្តបាត់ដំបង បណ្តាញអង្គការខេត្តសៀមរាប បណ្តាញអង្គការខេត្តកំពត និងបណ្តាញអង្គការខេត្តក្រចេះ ជាដើម។

យោងតាមស្ថានភាពនៃដំណើរការប្រែប្រួល និងបញ្ហាតម្រូវការ ព្រមទាំងសារតាដូចដែលបានរៀបរាប់ខាងលើ អង្គការ CCC និងរួមសហកាជាមួយ បណ្តាញអង្គការមិនមែនរដ្ឋាភិបាលខេត្តក្រចេះ និងចូលរួមរៀបចំពីអង្គការ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា បានផ្តួចផ្តើមសហការរៀបចំ អោយមានសិក្ខាសាលាថ្នាក់តំបន់មួយ ស្តីពី **និន្នាការអភិវឌ្ឍន៍ សម្រាប់សង្គមស៊ីវិល**[1] ដែលនឹងប្រព្រឹត្តិទៅនា **ល្ងាចថ្ងៃទី៣១ ខែតុលា និងព្រឹកថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧** នៅសណ្ឋាគារ ហ៊ា ប៊ុន្នី ក្នុងទីរួមខេត្តក្រចេះ ដែលមានសមាសភាពចូលរួមពីថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងមន្ត្រីកម្មវិធី តំណាងអាជ្ញាធរពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដែលមានចំនួនសរុបប្រមាណ ៥០ នាក់។

## គោលបំណងសិក្ខាសាលា

សិក្ខាសាលាថ្នាក់តំបន់នេះ មានគោលបំណងដើម្បីៈ

- ចែករំលែក និងធ្វើបច្ចុប្បន្នភាពនូវគោលនយោបាយផ្សេងៗសម្រាប់សង្គមស៊ីវិល (រួមមានគម្រោងអភិវឌ្ឍថ្នាក់ក្រោមជាតិ (ផអ៣) និងការអនុវត្តផែនការគណនេយ្យភាពសង្គម (ISAF) ផែនការអភិវឌ្ឍប្រកបដោយចីរភាព ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីពន្ធដារជាដើម)។
- ពិភាក្សាលើវឌ្ឍនភាព និង បញ្ហាប្រឈមផ្សេងៗ សម្រាប់អង្គការសង្គមស៊ីវិលថ្នាក់ខេត្ត ព្រមទាំងគោលការណ៍អភិបាលកិច្ចសម្រាប់អង្គការសហគមន៍មូលដ្ឋាន
- ចែករំលែក និងវាយតម្លៃសម្រាប់យុទ្ធសាស្ត្រក្នុងការប្រាស្រ័យទាក់ទង និងបណ្តាញទំនាក់ទំនងសង្គមសម្រាប់សង្គមស៊ីវិលសម្រាប់ការងារអភិវឌ្ឍន៍ ។

## សមាសភាពចូលរួម និងទីកន្លែង

សិក្ខាសាលាថ្នាក់តំបន់នេះ នឹងរៀបចំឡើងនៅសណ្ឋាគារ ហ៊ា ប៊ុន្នី ក្នុងទីរួមខេត្តក្រចេះ ដោយមានសមាសភាពចូលរួមប្រមាណ ៥០នាក់ ដែលអញ្ជើញចូលរួមមានពីតំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត អង្គការសមាជិកភាពរបស់អង្គការ CCC អង្គការសហគមន៍មូលដ្ឋាន តំណាងអាជ្ញាធរ និងអង្គការដៃគូអភិវឌ្ឍផ្សេងទៀត ដែលអញ្ជើញមកពីខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគីរី និងខេត្តរតនៈគីរី។

[1] ថវិកាមួយផ្នែកគាំទ្រពីគម្រោង "ពង្រឹងសង្គមស៊ីវិល ដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ និងប្រកបដោយចីរភាពនៅកម្ពុជា" ដែលឧបត្ថមដោយសហគមន៍អឺរ៉ុប (EU) និងប្រែតហ្វជីវីល (Bread for the World)។

## លទ្ធផលរំពឹងទុក

- អង្គការចូលរួមមកពីខេត្តនៅតំបន់ឥសានមានការយល់ដឹង និងអាចអនុវត្តបានកាន់តែប្រសើរ ស្របតាមគោលនយោបាយផ្សេងៗ និងដំណើរការអភិវឌ្ឍន៍ (រួមមានផែនការអភិវឌ្ឍប្រកបដោយចិរភាព ផែនការនិងការអនុវត្តថ្នាក់ក្រោមជាតិ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីពន្ធដារ ជាដើម។
- ការស្វែងយល់ពីគ្នាទៅវិញទៅមកកាន់តែប្រសើរសម្រាប់អង្គការការសង្គមស៊ីវិលសម្រាប់ជាសាមាជិក មិនមែនសមាជិក និងកសាងការងារបណ្តាញ ហើយព្រមទាំងយល់ដឹងស៊ីជម្រៅលើគោលការណ៍និងផែនការអភិបាលកិច្ចសម្រាប់អង្គការសហគមន៍មូលដ្ឋាន។
- ការប្រាស្រ័យទាក់ទងគ្នាកាន់តែមានប្រសិទ្ធភាពសម្រាប់អង្គការសង្គមស៊ីវិល ពិសេសការរៀបចំ និងប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងសង្គម សម្រាប់យុទ្ធសាស្ត្រក្នុងការទំនាក់ទំនង។

**កម្មវិធីព្រឹកប្រជុំបណ្តាញខេត្តក្រចេះ**

| ពេលវេលា | កម្មវិធី | អ្នកសម្របសម្រួល |
|---|---|---|
| ព្រឹក<br>(8:30-12:00) | - ពិភាក្សាការងារបណ្តាញអង្គការខេត្តក្រចេះ<br>- ប្រព័ន្ធទំនាក់ទំនង និងផ្សព្វផ្សាយសង្គម សម្រាប់សង្គមស៊ីវិល | **-លោក ថាច់ មេត្រី**<br>ប្រធានបណ្តាញ និងអ្នកសម្របសម្រួលអង្គការ Recoftc<br>**-លោក ព្រំ វាសនា**<br>អ្នកឯកទេសទំនាក់ទំនង អង្គការ CCC |

## របៀបវារៈសម្រាប់សិក្ខាសាលាថ្នាក់តំបន់

| ពេលវេលា | កម្មវិធី | អ្នកសម្របសម្រួល |
|---|---|---|
| **ល្ងាចថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧** | | |
| 1:15-1:30 | **ការចុះឈ្មោះចូលរួមភ្ញៀវកិត្តិយល និងគណៈអធិបតី** | អង្គការ CCC និងបណ្តាញអង្គការខេត្ត |
| 1:30-1:45 | **ការបើកកម្មវិធីសិក្សាថ្នាក់តំបន់**<br>- គោរពភ្លេងជាតិ<br>- បង្ហាញពីកម្មវិធី<br>- កិច្ចសុន្ទកថាស្វាគមន៍ និងបើកកម្មវិធី | អ្នកកាន់កម្មវិធី<br>- **ឯកឧត្តម វ៉ា ថន**<br>អភិបាលរងខេត្តក្រចេះ |
| 1:45-3:00 | **វគ្គទី១៖ ការធ្វើបច្ចុប្បន្នភាព**<br>- ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល<br>- ច្បាប់ស្តីពីពន្ធដារ<br>**សំនួរ - ចម្លើយ** | - **លោក កែវ ឌីណា**<br>ប្រធានកម្មវិធី អង្គការជំនួយផ្នែកច្បាប់កម្ពុជា |
| 3:00 -3:50 | **វគ្គទី១៖ ការធ្វើបច្ចុប្បន្នភាព និងពិភាក្សា**<br>- គម្រោងអភិវឌ្ឍថ្នាក់ក្រោមជាតិ (ផអ៣) និងការអនុវត្តផែនការគណនេយ្យភាពសង្គម (ISAF)<br>- ផែនការអភិវឌ្ឍប្រកបដោយចីរភាព (CSDGs) | - **លោក សៀង សារឿន**<br>នាយកប្រតិបត្តិ អង្គការ CCC |

| | | |
|---|---|---|
| | **សំនួរ - ចម្លើយ** | |
| 3:50- 4:05 | សំរាកអាហារសំរ៉ន់ | |
| 4:05– 4:30 | **វគ្គទី២៖ វឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការងារអភិវឌ្ឍន៍សម្រាប់សង្គមស៊ីវិល**<br>វឌ្ឍនភាព និងបញ្ហាប្រឈមតាមក្នុងខេត្តនីមួយៗ | - **លោក ថាច់ មេត្រី**<br>ប្រធានបណ្តាញ អង្គការខេត្ត និងអ្នកសម្របសម្រួលអង្គការ Recoftc |
| 4:30– 5:00 | **វគ្គទី៣៖ ពិភាក្សាក្រុមពីយន្តការ និងដំណើរការសម្រាប់សង្គមស៊ីវិល**<br>1. តើគួរធ្វើដូចម្តេច ដើម្បីរៀបចំយុទ្ធសាស្រ្តក្នុងដោះស្រាយបញ្ហាប្រឈមផ្សេងៗ ដែលបានលើកឡើង?<br>2. តើគួរធ្វើដូចម្តេច ក្នុងការត្រៀមខ្លួន ដើម្បីឆ្លើយតបតាមគោលនយោបាយ និងការអនុវត្តតាមច្បាប់និងបទដ្ឋានគតិយុត្តិទាំងនេះ?<br><br>**ការចែករំលែកលទ្ធផលសង្ខេបតាមក្រុម** | - **លោក ស៊ុត សាមឌី**<br>អ្នកឯកទេសសហគមន៍<br>អង្គការ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា |
| 5:00-5:20 | **វគ្គទី៤៖ ការផ្សព្វផ្សាយ និងវាយតម្លៃ**<br>- ការផ្សព្វផ្សាយពីសមាជិកភាព និងឪកាសផ្សេងៗសម្រាប់អង្គការសង្គមស៊ីវិល<br>- ការវាយតម្លៃលើគោលការណ៍សម្រាប់ទំនាក់ទំនង | - **លោក ជេន សុជឿន**<br>អ្នកស្រាវជ្រាវ និងអភិវឌ្ឍន៍សមាជិកភាព<br>អង្គការ CCC |
| 5:20-5:30 | **សរុបកម្មវិធី** | - **លោក ថាច់ មេត្រី**<br>ប្រធានបណ្តាញ និងអ្នកសម្របសម្រួលអង្គការ Recoftc |
| **ព្រឹកថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧** | | |
| 8:00-8:30 | **ការចុះឈ្មោះអ្នកចូលរួម** | អង្គការ CCC និងបណ្តាញអង្គការខេត្ត |
| 8:30-8:50 | **ណែនាំ និងស្វាគមន៍ សម្រាប់កិច្ចប្រជុំព្រឹកបន្ទាប់** | អង្គការ CCC និងបណ្តាញអង្គការខេត្ត |
| 8:50-10:10 | **បទបង្ហាញ អពីការអភិវឌ្ឍគម្រោង និងគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននៅកម្ពុជា** | - **លោក ឈន វឌ្ឍនៈ**<br>អ្នកគ្រប់គ្រងផ្នែកអភិបាលកិច្ចនិងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ<br>- **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសអង្គការសហគមន៍មូលដ្ឋាន |
| 10:10- 10:25 | សំរាកអាហារសំរ៉ន់ | |
| 10:25-11:40 | ការពិភាក្សាក្រុមតូចស្តីពីយន្តការសម្រាប់ភាពជាដៃគូរវាងអង្គការបណ្តាញ ដើម្បីគាំទ្រដល់អង្គការសហគមន៍មូលដ្ឋានក្នុងការលើកកម្ពស់និងបណ្តុះវប្បធម៌នៃការប្រតិបត្តិល្អ និងនិរន្តរភាព | - **លោក ឈន វឌ្ឍនៈ**<br>អ្នកគ្រប់គ្រងផ្នែកអភិបាលកិច្ចនិងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ<br>- **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសអង្គការសហគមន៍មូលដ្ឋាន |
| 11:40-12:00 | សរុប និងបិទកម្មវិធី | - **លោក សឿង សារឿន**<br>នាយកប្រតិបត្តិអង្គការ CCC |
| 12:00-1:00 | អាហារថ្ងៃត្រង់រួមគ្នា | អ្នកចូលរួមទាំងអស់គ្នា |

**សំគាល់៖** អ្នករៀបចំកម្មវិធីសូមរក្សាសិទ្ធិក្នុងការកែប្រែរបៀបវារៈក្នុងករណីចាំបាច់។